# **កាឡាទី ៤:៨-៣១**

**ការរំលឹក** នៅក្នុងកាឡាទី ៣:២៦-៤:៧ យើងរៀនបានថា គ្រីស្ទបរិស័ទគឺជាកូនព្រះនិងជាពូជរបស់អ័ប្រាហាំដោយសារយើងជឿលើព្រះគ្រីស្ទ។ ឥឡូវនេះយើងនៅសម័យថ្មី ហើយលែងនៅក្រោមអំណាចរបស់ក្រិត្យវិន័យទៀតហើយ ពីព្រោះព្រះគ្រីស្ទបានយាងមកហើយ។

សូមអានកាឡាទី ៤:៨-៣១ ទាំងមូល។
សូមអាន ខ.៨-១១។ *មុនពួកកាឡាទីបានស្គាល់ព្រះ តើគេបានជាប់បំរើនរណា?*
*ពួកកាឡាទីត្រឡប់ទៅអ្វីវិញ? (ខ.៩-១០)*

**ការពន្យល់ និងសំនួរជជែក** មុនពេលគ្រីស្ទបរិស័ទនៅកាឡាទីបានទទួលព្រះគ្រីស្ទ គេធ្លាប់បានដើរតាមសាសនានិងប្រពៃណីរបស់មនុស្សលោកដែលមិនស្គាល់ព្រះជាម្ចាស់។ ពីមុនគេតាមបឋមសិក្សាដែលខ្សោយហើយទាបថោកទាំងនោះពីព្រោះគេមិនស្គាល់ព្រះជាម្ចាស់ទេ ប៉ុន្តែលោកប៉ុលឆ្ងល់ណាស់ថា ឥឡូវគេបានស្គាល់ព្រះជាម្ចាស់ហើយ ប៉ុន្តែគេបែរទៅបម្រើវិញ្ញាណនិងប្រពៃណីរបស់លោកិយនេះទៅវិញ។ ដូច្នេះ គេត្រឡប់ទៅស្ថានភាពពីមុន ប៉ុន្តែនៅក្នុង ៤:១-៧ លោកប៉ុលបានបង្រៀនថា ឥឡូវនេះយើងបានដល់សម័យថ្មី ហើយអស់អ្នកនៅក្នុងព្រះគ្រីស្ទគឺជាកូនរបស់ព្រះអង្គ។ ប្រសិនបើគេត្រឡប់ទៅតាមបឋមសិក្សា ខ្សោយហើយទាបថោក នោះការនឿយហត់ដែលលោកប៉ុលធ្វើសំរាប់ពួកគេត្រឡប់ទៅជាឥតប្រយោជន៍វិញ។ *តើ អ្នកធ្លាប់ឃើញគ្រីស្ទបរិស័ទត្រឡប់ទៅតាមប្រពៃណីរបស់លោកិយនេះដោយកាន់តាមថ្ងៃ ខែ រដូវ និងឆ្នាំផ្សេងៗ ដែរឬទេ?*

សូមអានខ.១២-១៦។
**ការពន្យល់ និងសំនួរជជែក** អត្ថបទនេះមានសេចក្តីខ្លះពិបាកយល់ ពីព្រោះលោកប៉ុលសរសេរអំពីព្រឹត្តិការណ៍ដែលកើតឡើងរវាងគាត់និងពួកកាឡាទី។ ទោះជាដូច្នេះក្តី ខ្លឹមសារនៃអត្ថបទនេះច្បាស់លាស់ហើយថាអាកប្បកិរិយារបស់គ្រីស្ទបរិស័ទនៅកាឡាទី (ជាពិសេសចំពោះលោកប៉ុល) បានផ្លាស់ប្តូរ។ ពីមុនគេបានទទួលលោកប៉ុលទុកដូចជាទេវតានៃព្រះ ប៉ុន្តែឥឡូវនេះគេបែរទៅតាមគ្រូដែលចង់ឱ្យគេចោលលោកប៉ុលវិញ។ នៅទីនេះលោកប៉ុលបានបើកចិត្តរបស់គាត់ពីព្រោះគាត់ព្រួយបារម្ភអំពីជំនឿរបស់ពួកគេ និងទំនាក់ទំនងរវាងគាត់និងពួកគេ។ *តើអ្នកធ្លាប់ឃើញអ្នកដឹកនាំពួកជំនុំបើកចិត្ត ពីព្រោះពួកគេព្រួយបារម្ភអំពីជំនឿនិងទំនាក់ទំនងឬទេ?*

សូមអាន ខ.១៧-២០។ *តើគ្រូក្លែងក្លាយមានគោលបំណងអ្វី?*

**ការពន្យល់ និងអនុវត្តៈ** គ្រូបង្រៀនគ្រីស្ទបរិស័ទនិងគ្រូគង្វាលមានគោលបំណងនាំមនុស្សទៅឯព្រះគ្រីស្ទ និងមានសេចក្តីឧស្សាហ៍ក្នុងការតាមព្រះគ្រីស្ទ។ អាកប្បកិរិយារបស់គ្រូក្លែងក្លាយគឺ គេចង់តែនាំមនុស្សឲ្យតាមគេ (សូមប្រៀបធៀបកាឡាទី ៤:១៧ និង កិច្ចការ ២០:២៩-៣០)។ ដូច្នេះ គ្រូអធិប្បាយ គ្រូគង្វាល បេសកជន គ្រូបង្រៀននៅក្នុងពួកជំនុំ គ្រូប្រកាសដំណឹងល្អ ត្រូវមានអាកប្បកិរិយាដូចជាលោកប៉ុលនៅក្នុង២កូរិនថូស ៤:៥ «យើងខ្ញុំមិនប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ គឺពីព្រះ

គ្រីស្ទយេស៊ូវជាព្រះអម្ចាស់វិញ ហើយក៏រាប់ខ្លួនយើងខ្ញុំ ថាជាបាវបំរើរបស់អ្នករាល់គ្នា ដោយព្រោះព្រះយេស៊ូវដែរ»។ គ្រូដែលមានអាកប្បកិរិយាបែបនេះសប្បាយចិត្ត បើសិនជាមានគ្រូផ្សេងៗទៀតនៅក្នុងពួកជំនុំ ដែលមានសមត្ថភាពជួយនាំសមាជិកទៅឯព្រះគ្រីស្ទ ហើយឥតមានចិត្តច្រណែនឬចង់កាន់អំណាចនោះ។

សូមអាន ៤.២១។

**ការពន្យល់:** ប្រហែលជាពួកកាឡាទីគិតថា សេចក្តីដែលលោកប៉ុលបានសរសេរគឺផ្ទុយពីគម្ពីរក្រិត្យវិន័យ។ ដូច្នេះនៅក្នុងអត្ថបទនេះគាត់នឹងបង្ហាញថា ក្រិត្យវិន័យតែម្តងបញ្ជាក់សេចក្តីបង្រៀនរបស់គាត់។

សូមអាន ៤.២២-២៣ ហើយបំពេញចន្លោះ ខាងក្រោម។ លោកអ័ប្រាហាំមានកូន ២ ដែលមួយកើតពី___________ ហើយមួយពី____________ តែកូនដែលកើតពីបាវស្រី នោះបានកើតតាម_______________ ហើយ១ដែលកើតពីអ្នកជា បានកើតតាម___________________។

សូមអាន ៤.២៤-២៦។ *ស្ត្រីទាំង២នេះជាគំរូពីអ្វី?*

*នាងហាការជាគំរូពីអ្វី?*

*«ម្តាយ» របស់គ្រីស្ទបរិស័ទគឺជានរណា?*

សូមអាន ៤.២៧-២៩។ *គ្រីស្ទបរិស័ទជាកូនតាមអ្វី?*

*តើ កូនណាបានធ្វើទុក្ខដល់កូនណា?*

*សូមអាន ៤.៣០-៣១។ តើ គម្ពីរថា ចូរដេញនរណាចេញទៅ?*

**ការពន្យល់** យើងត្រូវកាត់ស្រាយអត្ថបទនៅក្នុងព្រះគម្ពីរដោយពិនិត្យមើលបរិបទរបស់វា។ យើងដឹងហើយថា លោកប៉ុលបានសរសេរសំបុត្រនេះដើម្បីដោះស្រាយបញ្ហាដែលមកពីគ្រូក្លែងក្លាយ ដែលចង់នាំពួកគ្រីស្ទបរិស័ទនៅកាឡាទីឲ្យអាងដល់ការប្រព្រឹត្តតាមក្រិត្យវិន័យ។ គាត់បានសរសេរហើយថា យើងមានសេរីភាពនៅក្នុងព្រះគ្រីស្ទយេស៊ូវ (២:៤) «យើងបានទទួល*សេចក្តីសន្យា* គឺជា ព្រះវិញ្ញាណ ដោយសារសេចក្តីជំនឿ» (៣:១៤) «បើអ្នករាល់គ្នាជារបស់ផងព្រះគ្រីស្ទ នោះអ្នករាល់គ្នាក៏ជាអ្នកគ្រងមរដកតាម*សេចក្តីសន្យា*ផងដែរ» (៣:២៩) «អ្នករាល់គ្នាមិនមែនជា*បាវបំរើ*ទៀតទេ គឺជា*កូន*វិញ ហើយបើជា*កូន* នោះនឹងបានមរដកនៃព្រះ ដោយសារព្រះគ្រីស្ទ» (៤:៧)។ ដូច្នេះ ផ្ទៃរឿងសំខាន់នៅក្នុងសំបុត្រនេះគឺជា តាមរយៈ*សេចក្តីជំនឿ*របស់យើងលើ*ព្រះគ្រីស្ទ* គ្រីស្ទបរិស័ទគឺជា*កូន*របស់ព្រះជាម្ចាស់ ដែលមាន*សេរីភាព* ហើយគ្រងមរដកតាម*សេចក្តីសន្យា* យើងមិនមែនជា*បាវបំរើ ដែល*ពឹងផ្អែកលើ*ក្រិត្យវិន័យ*ទៀតទេ។ ដូច្នេះ លោកប៉ុលបានលើកយកឧទាហរណ៍មួយមកពីក្រិត្យវិន័យ ដែលស្តីអំពីបាវស្រីនិងស្រីអ្នកជាថា «យើងរាល់គ្នាមិនមែនជាកូនរបស់បាវស្រីទេ គឺជាកូនរបស់ស្រីអ្នកជាវិញ» (៤:៣១)។ កាឡាទីជំពូកប្រាំនឹងពន្យល់ហើយអនុវត្តសេចក្តីបង្រៀននេះបន្ថែមទៀត។

**រំលឹកឡើងវិញ** តើយើងបានរៀនអ្វីខ្លះចេញពីកាឡាទី ៤:៨-៣១?